# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 1428

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : គម្រោងកែលម្អផ្លូវជនបទតភ្ជាប់តំបន់ឆ្នេរសមុទ្រ

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 01/01/25 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 31/12/27 |

៣. ចំណាយគម្រោងសរុប $75,000,000

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងអភិវឌ្ឍន៍ជនបទ

| | |
|---|---|
| RESPONSIBLE UNIT | Rural Road Department |
| អង្គភាពទទួលខុសត្រូវ | នាយកដ្ឋានផ្លូវលំជនបទ |

៥. ស្ថានភាពគម្រោង គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងវិនិយោគជាទុន

៧. ប្រភពហិរញ្ញប្បទាន៖ បញ្ចូលក្នុងវាងចរិការ និងឥណទានផ្សេងៗ

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្រ្តបញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី៣- ការលើកស្ទួយកសិកម្ម និងការអភិវឌ្ឍជនបទ

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

ការធ្វើឱ្យប្រសើរឡើងនូវភាពធន់បម្រែបម្រួលអាកាសធាតុនៃហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនជនបទដោយការតភ្ជាប់បណ្តាញផ្លូវទៅកាន់តំបន់ឆ្នេរ។ ការវិនិយោគនេះនឹងរួម ចំណែកដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយភាព ក្រីក្ររបស់ រដ្ឋាភិបាល តាមរយៈ ការពង្រឹ ងការតភ្ជា ប់ ទៅ កាន់ទីផ្សារ ការប្រកបការងារ ធ្វើឱ្យប្រសើរឡើងនូវការអប់រំគ្រប់រដូវកាល និងសេវាសុខា ភិផ្សេង ៗ និងកាត់បន្ថយថ្លៃដឹកជញ្ជូន និងចំណេញពេលវេលាធ្វើដំណើរក្នុងការប្រកបអាជីវកម្មនៅក្នុងតំបន់គម្រោង។ល។

- ផ្តល់ការអភិវឌ្ឍន៍ធនធានមនុស្ស និងសេវាសង្គមតាមរយៈការធ្វើឱ្យប្រសើរឡើងនូវការតភ្ជាប់ទៅកាន់តំបន់សាលារៀន មន្ទីរពេទ្យ ឬមណ្ឌល សុខភាព ភូមិឃុំ និងកាត់បន្ថយអត្រាមរណៈឬពិការភាព តាមរយៈការកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ ។

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៏វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? គាំទ្រ

វិធានការគន្លឹះបួនជាក់ស្តែង (ថាមពល ការដឹកជញ្ជូន គោលនយោបាយដឹកជញ្ជូន និងការគ្រប់គ្រងការដឹកជញ្ជូន)

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

ការដឹកជញ្ជូន

១២. ទីតាំងអនុវត្តគម្រោង (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

កោះកុង, កែប, ព្រះសីហនុ, កំពត,

១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

គោលបំណងនៃគម្រោងគឺដើម្បីកែលម្អផ្លូវឱ្យមានភាពធន់នឹងអាកាសធាតុតាមរយៈការតភ្ជាប់តំបន់សេដ្ឋកិច្ច និងសង្គមក្នុង ខេត្ត ជាប់ឆ្នេរសមុទ្រ។ ដើម្បីកំណត់សមិទ្ធិផលនៃគម្រោងនេះ សូចនាករនឹងត្រូវស្នើឡើងសម្រាប់វាស់វែងដូចខាងក្រោម៖

- ប្រវែងផ្លូវជនបទត្រូវបានធ្វើឱ្យប្រសើរឡើងជាមួយនឹងវិធានការធន់នឹងអាកាសធាតុ (គីឡូម៉ែត្រ)
- ចំនួនស្ពានត្រូវបានជួសជុល/ធ្វើឱ្យប្រសើរឡើងជាមួយនឹងភាពធន់នឹងអាកាសធាតុ
- ចំនួនប្រជាជនដែលបានចំណេញថេរវេលាក្នុងការធ្វើដំណើរការទៅទទួលសេវាសេដ្ឋកិច្ច និងសង្គម
  -ផ្នែកសេដ្ឋកិច្ច៖ ចំនួនប្រជាជនដែលបានចំណេញថេរវេលាក្នុងការធ្វើដំណើរការទៅទីផ្សារ(ចំនួន)
  -ផ្នែកសង្គម៖ ចំនួនប្រជាជនដែលបានចំណេញថេរវេលាក្នុងការធ្វើដំណើរការទៅសាលារៀន មន្ទីរពេទ្យបង្អែក ឬមណ្ឌល សុខភាព

  ភូមិឃុំ ប្រៃសណីយ៍ សេវាសាធារណៈ ជាដើម។
- អ្នកជនបទអាចប្រើប្រាស់ផ្លូវពេញមួយឆ្នាំ (លទ្ធភាពប្រើប្រាស់)
- អ្នកទទួលផលពីគម្រោងសរុប (ចំនួន)

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

ផ្លូវថ្នល់មានសារៈសំខាន់ណាស់សម្រាប់មធ្យោបាយដឹកជញ្ជូននៅកម្ពុជាទាំងនៅទីក្រុង និងជនបទ។ ផ្លូវថ្នល់នៅ កម្ពុជា ត្រូវបាន តភ្ជាប់ បណ្តាញ ពីទីក្រុងទៅជនបទ ដែលមានប្រវែងសរុបប្រហែល63,134 គីឡូម៉ែត្រ រួមមានផ្លូវជាតិ ផ្លូវខេត្ត និង ផ្លូវជនបទ។
ផ្លូវជាតិមានប្រមាណ ៧ ២៦១ គីឡូម៉ែត្រ ផ្លូវខេត្តមាន ៩ ០៣១ គីឡូម៉ែត្រ និងផ្លូវជនបទ ៤៦ ៨៤២ គីឡូម៉ែត្រ។
ក្រសួងអភិវឌ្ឍន៍ជនបទ ទទួលខុសត្រូវលើការគ្រប់គ្រងផ្លូវជនបទ ចំណែកក្រសួងសាធារណការ និងដឹកជញ្ជូន ទទួលខុសត្រូវ គ្រប់ គ្រង ផ្លូវជាតិ និងខេត្ត។ ក្នុងចំណោមបណ្តាញផ្លូវជនបទសរុប ផ្លូវនៅក្នុងខេត្តជាប់មា ត់សមុទ្រមានប្រវែងសរុបប្រមាណ២៧៦០ គីឡូម៉ែត្រ ។
ផ្លូវដែលបានក្រាលកៅស៊ូមានប្រហែល ៥% និង ៩៥%ជាផ្លូវដែល មិនទាន់បានក្រាលកៅស៊ូ ហើយក្នុងចំណោម
ផ្លូវជនបទមិនទាន់ក្រាល កៅ ស៊ូ៦២% ជាផ្លូវថ្មបាយក្រៀម ឬក្រួស។ ផ្លូវជនបទភាគច្រើន ជាផ្លូវមិនទាន់បានក្រាលកៅស៊ូ
និងស្ពានភាពខូចខាត ច្រើនពិបាកធ្វើ ដំណើរដោយសារការថែទាំមិនបានគ្រប់គ្រាន់។ តាមរយៈគម្រោងនេះ
ផ្លូវនៅក្នុងតំបន់ឆ្នេរក្នុងផែនការ៣ឆ្នាំពីឆ្នាំ ២០២៥ ដល់ ២០២៧ មានធ្វើការកែលម្អផ្លូវប្រវែងសរុប ៣០០គីឡូម៉ែត្រ។

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

គម្រោងនេះត្រូវបានបង្កើតឡើងជាចម្បងគឺការតភ្ជាប់ផ្លូវជនបទនៅក្នុងតំបន់ជាប់មាត់សមុទ្រឱ្យមានភាពធន់នឹងអាកាសធាតុ និង ធានាបាន នូវល ទ្ធភាពប្រើប្រាស់គ្រប់រដូវ សម្រាប់ ការអភិវឌ្ឍន៍ជនប ទ។ ការស្តារឡើងវិញនូវ ផ្លូវជនបទដែលរង គ្រោះដោយទឹ កជំនន់នា នេះ និងជាគោលដៅសម្រាប់ខេត្តជាប់ឆ្នេរសមុទ្រដែលរងផលប៉ះពាល់ភាគច្រើន។ ក្នុងចំណោមផ្លូវទាំងអស់ មានតែផ្លូវដែលជាឆ្អឹងខ្នង ប៉ុណ្ណោះ ដែលត្រូវបានផ្តល់អាទិភាពក្នុងការកែលម្អឱ្យមាននិរន្តរភាព និងធន់នឹងអាកាសធាតុ និង បម្រើ ដល់បណ្តាញផ្លូវ សេដ្ឋ កិ ច្ច។ ការធ្វើឲ្យប្រសើរឡើងនូវការតភ្ជាប់ជនបទនៅតំបន់ជាប់សមុទ្រ គឺដើម្បីលើកកម្ពស់ជីវភាពនៃប្រជាជនក្នុងតំបន់គម្រោងក៏ដូចជាជួយបង្កើនការអភិវឌ្ឍន៍ សេដ្ឋ កិច្ច ជាតិ ជាមួយការលូតលាស់ផ្នែកសង្គម និងសេដ្ឋកិច្ច។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

គម្រោងនេះត្រូវបានគេរំពឹងថានឹងផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនជាងមួយលាននាក់ ដែលភាគច្រើនជាប្រជាជននៅ តាមជន បទក្នុងខេត្ត ជាប់មាត់សមុទ្រមានដូចជា ខេត្តព្រះសីហនុ កំពត កោះកុង និងកែប ក្នុងនោះប្រហែល70% នៃអ្នកទទួលផលជាស្ត្រី។

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? **មាន**

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? **មិនទានចាប់ផ្តើម**

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**វិធីសាស្ត្រដែលត្រូវបានយកមកអនុវត្តសម្រាប់ការកែលម្អផ្លូវជនបទគឺត្រូវបានពិចារណាលើគ្រប់ទិដ្ឋភាព ជាពិសេស គឺផ្តោតទៅលើហេតុប៉ះពាល់បរិស្ថាន និងសង្គមជាមួយអ្នកពាក់ព័ន្ធ និងសហគមន៍ទាំងអស់តាមរយៈការពិគ្រោះយោបល់ជាសាធារណៈ។**

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **មាន**

ប្រសិនបើទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ សូមជ្រើសរើស **ការបន្សាំ**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
| --- | --- | --- |
| **១៥. ការកែលម្អផ្លូវថ្នល់ រួមមានការគិតគូរពីការប្រែប្រួលអាកាសធាតុ** | 50 | **ទាក់ទងមធ្យម** |

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **មាន**

ប្រសិនបើ ទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយ សូមជ្រើសរើស **ការត្រៀម**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**សម្រាប់គម្រោងនេះ ការវិភាគយេនឌ័រធិនឹងត្រូវធ្វើឡើង និងបញ្រ្ជាបយេនឌ័រនឹងត្រូវបានផ្តល់សិទ្ធិយ៉ាងហោចណាស់ 20% នៃស្ត្រីក្នុងតំបន់គម្រោងត្រូវបានផ្តល់ការងារក្នុងវិស័យផ្លូវដោយមានវិធានសុវត្ថិភាពជាចម្បង។ ជាមួយនឹងបញ្ហាយេនឌ័រនេះ គម្រោងនេះនឹងរៀបចំវគ្គបណ្តុះបណ្តាលស្តីអំពើហឹង្សាយេនឌ័រជាមូលដ្ឋាន និង អំពើហិង្សាប្រឆាំងនឹងកុមារ ហើយនាយកដ្ឋានផ្លូវលំជនបទ នឹងរៀបចំបង្កើតផែនការសកម្មភាពយេនឌ័រ ដើម្បីអ្នកអនុវត្តគម្រោងប្រណិបត្តិ។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**បាទឬចាស់វាពិតណាស់។ MRD/RRD មានមន្ត្រីបច្ចេកទេសដែលមានសមត្ថភាពដើម្បីអនុវត្តគម្រោងនេះ។**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

**កំពុងចាប់ផ្តើមការសិក្សាសម្មិទ្ធិ**

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

**រួមបញ្ចូលគ្នាថវិកាជាតិ ឬហិរញ្ញប្បទានដៃគូ**

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 1,000.0 | 1,000.0 | 1,000.0 | 3,000.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 700.0 | 700.0 | 700.0 | 2,100.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 300.0 | 300.0 | 300.0 | 900.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 23,980.0 | 23,980.0 | 24,040.0 | 72,000.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 22,000.0 | 22,000.0 | 22,000.0 | 66,000.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 1,000.0 | 1,000.0 | 1,000.0 | 3,000.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 650.0 | 650.0 | 700.0 | 2,000.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 330.0 | 330.0 | 340.0 | 1,000.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 0.0 | 24,980.0 | 24,980.0 | 25,040.0 | 75,000.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ថវិកាជាតិ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 0.0 | 24,980.0 | 24,980.0 | 25,040.0 | 75,000.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: